# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

# កូនសៀវភៅ
# ស្តីពី
# សិទ្ធិនិងភាគព្វកិច្ចរបស់សមាជិកនិងថ្នាក់ដឹកនាំ សហគមន៍កសិកម្ម

រៀបចំដោយ៖ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

ខែមករា ឆ្នាំ២០១៦

**កូនសៀវភៅស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់សមាជិកនិងថ្នាក់ដឹកនាំសហគមន៍កសិកម្ម**
បោះពុម្ពផ្សាយ៖ ខែមករា ឆ្នាំ២០១៦
បោះពុម្ពដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម (MAFF)
គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)
អស័យដ្ឋាន៖ # ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់ ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ
ប្រទេសកម្ពុជា
ទូរស័ព្ទ៖ (០២៣) ៨៨៣ ៤២៧ ទូរសារ៖ (០២៣) ៨៨៣ ៤២៧
© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# មាតិកា


១. ហេតុផលនៃការចងក្រងកូនសៀវភៅស្តីពីសិទ្ធិនិងភាតព្វកិច្ចរបស់សមាជិកនិងថ្នាក់ដឹកនាំសហគមន៍កសិកម្ម ........ ១
២.សិទ្ធិរបស់សមាជិកសហគមន៍កសិកម្ម ........ ២
៣.ភាតព្វកិច្ចរបស់សមាជិកសហគមន៍កសិកម្ម ........ ៣
៤. ភារកិច្ចនិងភាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ........ ៤
៥. សិទ្ធិនិងភាតព្វកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យ ........ ៥

## ១ .ហេតុផលនៃការចងក្រងកូនសៀវភៅស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់សមាជិកនិងថ្នាក់ដឹកនាំសហគមន៍កសិកម្ម

សមាជិកសហគមន៍កសិកម្ម មានសិទ្ធិនិងកាតព្វកិច្ចសំខាន់ណាស់ ក្នុងការធ្វើឱ្យសហគមន៍កសិកម្ម មានដំណើរការទៅមុខ និងធ្វើឱ្យសហគមន៍កសិកម្មមានការរីកចម្រើន ពីព្រោះសមាជិកសហគមន៍កសិកម្ម ទាំងអស់ គឺជាម្ចាស់របស់សហគមន៍កសិកម្ម ។ ហេតុដូច្នេះ ការប្រើប្រាស់សិទ្ធិ និងការបំពេញកាតព្វកិច្ចឱ្យ បានត្រឹមត្រូវរបស់សមាជិក គឺជាកត្តាកំណត់ភាពជោគជ័យ របស់សហគមន៍កសិកម្ម ។ ជាការកត់សម្គាល់ នាពេលបច្ចុប្បន្ននេះ សមាជិកសហគមន៍កសិកម្មភាគច្រើនពុំទាន់បានយល់ច្បាស់ពីសិទ្ធិ និងកាតព្វកិច្ច របស់ខ្លួនចំពោះសហគមន៍កសិកម្មឡើយ ។ បញ្ហានេះ បណ្តាលមកពីសហគមន៍កសិកម្មភាគច្រើន ពុំទាន់ បានផ្សព្វផ្សាយ អប់រំនិងបណ្តុះបណ្តាល ដល់សមាជិកខ្លួនអំពីសិទ្ធិនិងកាតព្វកិច្ច ។

ដូចគ្នានេះដែរ ក្រុមប្រឹក្សាភិបាល ដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រតិបត្តិមុខរបរ និងដំណើការ សហគមន៍កសិកម្ម ឱ្យបានរលូននិងរីកចម្រើន ។ ចំណែកឯគណៈកម្មាធិការត្រួតពិនិត្យវិញ មានភារកិច្ច ត្រួតពិនិត្យសកម្មភាពរបស់ក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិដើម្បីរក្សាគណនេយ្យភាពដល់សមាជិក របស់សហគមន៍កសិកម្ម ។ ជាការកត់សម្គាល់ នាពេលបច្ចុប្បន្ននេះ សមាជិកក្រុមប្រឹក្សាភិបាលនិងគណៈ កម្មាធិការត្រួតពិនិត្យមួយចំនួនធំ ពុំទាន់យល់ពីតួនាទីនិងភារកិច្ចរបស់ខ្លួន ដែលបានចែងនៅក្នុងច្បាប់ស្តីពី សហគមន៍កសិកម្មឱ្យបានច្បាស់លាស់នៅឡើយទេ ដោយសារពុំបានសិក្សាស្វែងយល់ឱ្យបានច្បាស់លើ ច្បាប់ស្តីពីសហគមន៍កសិកម្ម។

ដោយសារមូលហេតុដូចបានរៀបរាប់ខាងលើនេះហើយ ទើបគម្រោងបង្កើតសហគមន៍កសិកម្មគំរូ ដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ(BPAC) ដែលត្រូវបានគាំទ្រដោយរដ្ឋាភិបាលជប៉ុនតាមរយៈអង្គការ JICA ប្រចាំនៅកម្ពុជា បានរៀបចំកូនសៀវភៅស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់សមាជិក និងថ្នាក់ដឹកនាំ សហគមន៍កសិកម្មនេះឡើង ដើម្បីផ្តល់ជូនសហគមន៍កសិកម្ម យកទៅធ្វើជាឯកសារផ្សព្វផ្សាយ អប់រំ និង បណ្តុះបណ្តាលដល់សមាជិកនិងថ្នាក់ដឹកនាំរបស់ខ្លួន សំដៅលើកកម្ពស់ការគ្រប់គ្រង និងការអភិវឌ្ឍ សហគមន៍កសិកម្មឱ្យមានការរីកចម្រើននិងមាននិរន្តភាព ។

## ២.សិទ្ធិរបស់សមាជិកសហគមន៍កសិកម្ម

អនុលោមតាមច្បាប់ស្តីពីសហគមន៍កសិកម្ម ដែលត្រូវបានប្រកាសដាក់ឱ្យប្រើកាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ បានកំណត់យ៉ាងច្បាស់ អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកសហគមន៍កសិកម្មក្នុងការចូលរួមអភិវឌ្ឍន៍សហគមន៍កសិកម្មរបស់ខ្លួន ។ យោងតាមមាត្រា៣១ នៃច្បាប់ស្តីពីសហគមន៍កសិកម្ម និងលក្ខន្តិកៈគំរូសម្រាប់សហគមន៍កសិកម្ម បានកំណត់អំពីសិទ្ធិរបស់សមាជិកសហគមន៍កសិកម្មដូចខាងក្រោម៖

- បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការត្រួតពិនិត្យសហគមន៍កសិកម្ម
- ទទួលព័ត៌មានស្តីពីសហគមន៍កសិកម្មខ្លួន ពីក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការត្រួតពិនិត្យ
- ស្នើសុំក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការត្រួតពិនិត្យ កោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីពិភាក្សាដោះស្រាយបញ្ហាចាំបាច់ណាមួយ ដែលខ្លួនបានរកឃើញពីភាពមិនប្រក្រតី ក្នុងករណីមានសមាជិកចំនួនមួយភាគបីនៃសមាជិកសហគមន៍កសិកម្មទាំងអស់បានឯកភាពស្នើសុំ
- លើកសំណើ សំណូមពរ ឬសំណួរជូនក្រុមប្រឹក្សាភិបាល គណៈកម្មាធិការត្រួតពិនិត្យ និងនាយកប្រតិបត្តិ អំពីបញ្ហាពាក់ព័ន្ធការអភិវឌ្ឍ ប្រតិបត្តិការនិងការគ្រប់គ្រងសហគមន៍កសិកម្ម ដែលតម្រូវឱ្យមានការឆ្លើយតបជាចាំបាច់
- ស្នើដាក់របៀបវារៈរបស់ខ្លួនចូលទៅក្នុងរបៀបវារៈនៃមហាសន្និបាតសហគមន៍កសិកម្ម
- ទទួលបានភាគលាភដោយអនុលោមតាមចំនួនភាគហ៊ុន ដែលសមាជិកម្នាក់ៗកាន់កាប់ និងទទួលបានរង្វាន់លើកទឹកចិត្តពីសហគមន៍កសិកម្ម ប្រសិនបើសហគមន៍កសិកម្ម មានប្រាក់ចំណេញ និងមានការបែងចែកដល់សមាជិក
- ជួលឬប្រើប្រាស់សេវាកម្ម និងមធ្យោបាយផលិតកម្មកសិកម្មនិងទីផ្សាររបស់សហគមន៍កសិកម្ម
- ចូលរួមគ្រប់សកម្មភាពរបស់សហគមន៍កសិកម្ម
- ចូលរួមធ្វើជំនួញជាមួយសហគមន៍កសិកម្ម
- អាចផ្ទេរភាគហ៊ុនមួយផ្នែកឬទាំងអស់ សិទ្ធិ អត្ថប្រយោជន៍ និងតួនាទីជាសមាជិកទៅសមាជិកដទៃទៀតនៃសហគមន៍កសិកម្មសាមី ដោយអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាត ប៉ុន្តែមិនអាចផ្ទេរឱ្យបុគ្គលផ្សេងទៀតដែលស្ថិតនៅក្រៅសហគមន៍កសិកម្មសាមីបានឡើយ

- ស្នើសុំលាឈប់ពីសមាជិកភាព នៃសហគមន៍កសិកម្មបាន ប៉ុន្តែត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាលដោយអនុលោមតាមការកំណត់ជាក់ស្តែងក្នុងលក្ខន្តិកៈរបស់សហគមន៍កសិកម្មខ្លួន
- ទទួលបានភាគហ៊ុនរបស់ខ្លួនវិញ បូកនឹងការប្រាក់ នៅពេលសុំលាឈប់ ឬត្រូវបណ្តេញចេញពីសហគមន៍កសិកម្មក្នុងករណីសហគមន៍កសិកម្មមានប្រាក់ចំណេញ
- ទទួលបានសិទ្ធិប្រយោជន៍ផ្សេងទៀតតាមការសម្រេចរបស់មហាសន្និបាតសហគមន៍កសិកម្ម។

## ៣.ភាតព្វកិច្ចរបស់សមាជិកសហគមន៍កសិកម្ម

អនុលោមតាមមាត្រា៣០ និងមាត្រា៣១នៃច្បាប់ស្តីពីសហគមន៍កសិកម្ម និងលក្ខន្តិកៈគំរូសម្រាប់សហគមន៍កសិកម្ម សមាជិកសហគមន៍កសិកម្មទាំងអស់មានកាតព្វកិច្ចដូចខាងក្រោម៖

- ចូលរួមមហាសន្និបាត និងបោះឆ្នោតដោយស្មើភាពគ្នាជាមួយសមាជិកដទៃទៀត ដោយពុំគិតពីកម្រិតភាគហ៊ុន ដែលកាន់កាប់នៅក្នុងសហគមន៍កសិកម្មឡើយ
- ត្រូវបង់ប្រាក់ភាគហ៊ុន ដែលខ្លួនបានទិញស្របតាមលក្ខខណ្ឌដូចមានចែងក្នុងលក្ខន្តិកៈ
- ធ្វើសហប្រតិបត្តិការជាមួយសមាជិកផ្សេងទៀត ដើម្បីចូលរួមកសាងសមត្ថភាព និងអភិវឌ្ឍន៍សហគមន៍កសិកម្ម
- ចូលរួមទទួលខុសត្រូវចំពោះបំណុល ហានិភ័យ ការខូចខាត និងរាល់ការបាត់បង់ទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មអនុលោមតាមលក្ខន្តិកៈរបស់សហគមន៍កសិកម្ម
- ក្នុងករណីបង្កការខូចខាតទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មផ្ទាល់ ត្រូវទទួលខុសត្រូវចេញសំណងឬជួសជុលការខូចខាតដោយអនុលោមតាមលក្ខន្តិកៈរបស់សហគមន៍កសិកម្ម
- នៅពេលលាឈប់ ឬត្រូវបណ្តេញចេញពីសមាជិកភាព ក្នុងករណីសហគមន៍កសិកម្មមានការខាតបង់ ត្រូវទទួលបន្ទុកបង់ខាតតាមសមាមាត្រនៃភាគហ៊ុន ដែលខ្លួនកាន់កាប់ ដោយអនុលោមតាមការកំណត់ក្នុងលក្ខន្តិកៈ ។
- ចូលរួមធ្វើជំនួញជាមួយសហគមន៍កសិកម្ម
- ជួលឬប្រើប្រាស់សេវាកម្ម និងមធ្យោបាយផលិតកម្មកសិកម្មនិងទីផ្សាររបស់សហគមន៍កសិកម្ម
- ការពារផលប្រយោជន៍របស់សហគមន៍កសិកម្ម
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត
- គោរព និងអនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់មហាសន្និបាតរបស់សហគមន៍កសិកម្ម ព្រមទាំងច្បាប់ស្តីពីសហគមន៍កសិកម្ម។

## ៤.ភារកិច្ចនិងភាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល

យោងតាមមាត្រា ៣៦ មាត្រា៤២ មាត្រា ៤៥ មាត្រា ៤៦ មាត្រា ៤៧ មាត្រា ៤៨ មាត្រា ៤៩ និង មាត្រា ៧០ នៃច្បាប់ស្តីពីសហគមន៍កសិកម្ម និងលក្ខន្តិកៈគំរូសម្រាប់សហគមន៍កសិកម្ម ក្រុមប្រឹក្សាភិបាល សហគមន៍កសិកម្ម មានភារកិច្ចនិងកាតព្វកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

- ទទួលខុសត្រូវលើកិច្ចការរដ្ឋបាលនិងដំណើរការគ្រប់គ្រងរបស់សហគមន៍កសិកម្ម ដោយសម្រេច លើរចនាសម្ព័ន្ធរបស់សហគមន៍កសិកម្ម និងធានាការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តី សម្រេចរបស់មហាសន្និបាតសហគមន៍កសិកម្ម
- ប្រតិបត្តិនិងអនុវត្ត បេសកកម្ម គោលនយោបាយមុខជំនួញ យុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការហិរញ្ញវត្ថុ និងភារកិច្ចផ្សេងទៀតដែលសម្រេចដោយមហាសន្និបាត ដូចមានចែងនៅក្នុង លក្ខន្តិកៈរបស់សហគមន៍កសិកម្ម និងបទដ្ឋានគតិយុត្ត ពាក់ព័ន្ធជាធរមាន
- រក្សាទុកឯកសារ ឬបញ្ជីសំខាន់ៗដែលរួមមាន លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ កសិកម្ម បញ្ជីសមាជិកសហគមន៍កសិកម្ម បញ្ជីភាគហ៊ុនរបស់សមាជិក របាយការណ៍ប្រចាំឆ្នាំរបស់ សហគមន៍កសិកម្ម កំណត់ហេតុនៃកិច្ចប្រជុំនិងរបាយការណ៍គ្រប់ប្រភេទ នៅក្នុងទីស្នាក់ការរបស់ សហគមន៍កសិកម្ម ឬកន្លែងណាមួយដែលសម្រេចដោយសហគមន៍កសិកម្មខ្លួន
- ធ្វើតំណាងជាម្ចាស់ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្ម
- លើកកម្ពស់សមត្ថភាព និងប្រសិទ្ធិភាពការងាររបស់ក្រុមប្រឹក្សាភិបាល បណ្តុះបណ្តាល កសាង សមត្ថភាពរបស់សមាជិក ដើម្បីបង្កើនភាពជឿជាក់មកលើសហគមន៍កសិកម្ម
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំខែរបស់ខ្លួន
- កោះអញ្ជើញនិងរៀបចំមហាសន្និបាតសហគមន៍កសិកម្ម
- ចូលរួមកិច្ចប្រជុំប្រចាំខែរបស់ខ្លួន
- ទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ ស្របតាមទម្រង់គណនេយ្យសម្រាប់សហគមន៍ កសិកម្ម
- រៀបចំ និងដាក់របាយការណ៍ប្រចាំឆ្នាំ និងតារាងតុល្យការ ដែលបញ្ជាក់ដោយគណៈកម្មាធិការត្រួត ពិនិត្យ ជូនមហាសន្និបាត ដើម្បីពិនិត្យនិងអនុម័ត
- រៀបចំនិងដាក់ផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទខាងមុខ ជូន មហាសន្និបាតដើម្បីពិនិត្យនិងអនុម័ត
- រៀបចំឯកសារចាំបាច់សម្រាប់សវនកម្មដែលច្បាប់តម្រូវ ព្រមទាំងរាយការណ៍ជូនមហាសន្និបាត
- រៀបចំប្រជុំមហាសន្និបាតវិសាមញ្ញរបស់សហគមន៍កសិកម្ម ក្នុងករណីចាំបាច់

- ផ្ញើរបាយការណ៍ប្រចាំឆ្នាំនិងតារាងតុល្យការដល់អង្គភាពចុះបញ្ជីរបស់ខ្លួន
- អាចជ្រើសរើសនាយកប្រតិបត្តិម្នាក់ ដែលអាចជាសមាជិក ឬមិនមែនជាសមាជិករបស់សហគមន៍កសិកម្មតែមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាលឬមិនមែនជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្ម ដើម្បីប្រតិបត្តិការមុខជំនួញ
- តាមដាននិងវាយតម្លៃលើការបំពេញភារកិច្ចរបស់នាយកប្រតិបត្តិ ដោយផ្អែកតាមលទ្ធផល អនុវត្តផែនការសកម្មភាព ផែនការហិរញ្ញវត្ថុ និងប្រសិទ្ធិភាពសេដ្ឋកិច្ចរបស់សហគមន៍កសិកម្ម
- អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាតាមការចាំបាច់ ដើម្បីបម្រើការងារក្នុងប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្ម ដោយអនុលោមតាមច្បាប់ស្តីពីការងារ
- ពិនិត្យលើពាក្យស្នើសុំចូលសមាជិកថ្មី ពាក្យស្នើសុំបញ្ឈប់ឬលុបចេញពីសមាជិកភាពរបស់សហគមន៍កសិកម្ម ដើម្បីដាក់ឆ្លងមហាសន្និបាត
- ត្រូវទទួលខុសត្រូវរៀងៗខ្លួនផង និងរួមគ្នាផង ចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់មហាសន្និបាតសហគមន៍កសិកម្ម ។

## ៥ .សិទ្ធិនិងភារកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យ

យោងតាមមាត្រា៥១ និងមាត្រា ៥២ នៃច្បាប់ស្តីពីសហគមន៍កសិកម្ម និងលក្ខន្តិកៈគំរូសម្រាប់សហគមន៍កសិកម្ម គណៈកម្មាធិការត្រួតពិនិត្យមានសិទ្ធិនិងកាតព្វកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងបណ្តាសេចក្តីសម្រេចរបស់មហាសន្និបាតរបស់សហគមន៍កសិកម្ម
- ត្រួតពិនិត្យលើសកម្មភាពរបស់ក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ ដើម្បីធានារាល់កិច្ចការទាំងឡាយរបស់សហគមន៍កសិកម្ម ឱ្យមានសង្គតិភាពជាមួយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ច្បាប់ស្តីពីសហគមន៍កសិកម្ម និងបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត
- ស្នើសុំឱ្យអ្នកពាក់ព័ន្ធក្នុងសហគមន៍កសិកម្ម ផ្តល់នូវឯកសារចាំបាច់ និងថតចម្លងឯកសារ ជាកម្មវត្ថុសម្រាប់ត្រួតពិនិត្យ
- ធ្វើការត្រួតពិនិត្យ ឬបញ្ជាឱ្យត្រួតពិនិត្យបញ្ជីគណនេយ្យ បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ តារាងតុល្យការ និងឯកសារហិរញ្ញវត្ថុផ្សេងទៀត ដែលកត់ត្រានូវស្ថានភាពមុខជំនួញនិងប្រតិបត្តិការហិរញ្ញវត្ថុរបស់សហគមន៍កសិកម្ម។
- ត្រូវរៀបចំកិច្ចប្រជុំការងាររបស់ខ្លួនយោងតាមការចាំបាច់
- ត្រូវជូនព័ត៌មានស្តីពីសភាពការណ៍ ដែលខ្លួនបានត្រួតពិនិត្យ ទៅក្រុមប្រឹក្សាភិបាល ហើយរៀបរាប់អំពីបញ្ហានេះ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ជូនមហាសន្និបាត

- ទទួលពាក្យបណ្ដឹង ការតវ៉ាពាក់ព័ន្ធនឹងប្រតិបត្តិការមុខជំនួញរបស់សហគមន៍កសិកម្មដើម្បីរកដំណោះស្រាយ ឬលើកសំណើជូនអង្គភាពមានសមត្ថកិច្ចដោះស្រាយលើបណ្ដឹង ឬការតវ៉ានោះស្របតាមលក្ខន្តិកៈនិងច្បាប់ជាធរមាន
- ស្នើឱ្យប្រធានក្រុមប្រឹក្សាភិបាលកោះប្រជុំ ឬបើកមហាសន្និបាតវិសាមញ្ញ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ជាក់លាក់ណាមួយរបស់សហគមន៍កសិកម្មខ្លួន
- រៀបចំរបៀបវារៈ និងកោះអញ្ជើញមហាសន្និបាតវិសាមញ្ញ នៅពេលកើតមានបញ្ហាចាំបាច់នៅក្នុងសហគមន៍កសិកម្ម ដើម្បីប្រជុំដោះស្រាយ តាមករណីដូចខាងក្រោម៖
    - កើតមានអំពើល្មើសណាមួយចំពោះច្បាប់ស្ដីពីសហគមន៍កសិកម្ម លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្ម ឬសេចក្ដីសម្រេចរបស់មហាសន្និបាត ដែលក្នុងនោះក្រុមប្រឹក្សាភិបាលខកខានមិនបានចាត់វិធានការចំពោះករណីល្មើសនោះ
    - ករណីក្រុមប្រឹក្សាភិបាលបានខកខានកោះអញ្ជើញមហាសន្និបាតវិសាមញ្ញដើម្បីដោះស្រាយបញ្ហាដោយអនុលោមតាមលក្ខន្តិកៈនេះ
- ធ្វើរបាយការណ៍ត្រួតពិនិត្យស្ដីពីប្រតិបត្តិការមុខជំនួញ និងការគ្រប់គ្រងទូទៅរបស់សហគមន៍កសិកម្ម និងរាយការណ៍ជូនមហាសន្និបាត នៅរាល់ដំណាច់ឆ្នាំសារពើពន្ធ

**Booklet on Rights and Obligations of Members and Officials of Agricultural Cooperative**

Printed in Januray 2016

Published by Department of Agricultural Cooperative Promotion of GDA (MAFF)

The Project for Establishing Business Oriented Agricultural Cooperative Models (BPAC)

Address: #54B/49F.St395-656,Sangkat Toeuk Laak 3 Khan Tuol Kok, Phnom penh ,Cambodia,

Phone: (023) 883 427, Fax : 023) 883 427

© The Project for Establishing Business-Oriented Agricultural Cooperative Models